# លោហកុម្ភិជាតក




*ព្រះសាស្ដាកាលស្ដេចគង់នៅវត្តជេតពន ទ្រង់ប្រារព្ធព្រះបាទកោសល បានត្រាស់ព្រះធម្មទេសនានេះ មានពាក្យថា* ***ទុជ្ជីវិតមជីវិម្ហ*** *ដូច្នេះជាដើម ។*

*បានឮមកថា ក្នុងគ្រានោះ ព្រះបាទកោសលស្ដាប់ឮសំឡេងសត្វនរកទាំង ៤ ក្នុងពេលរាត្រី ។ សត្វនរកមួយពោល**ទុអក្សរ**, សត្វនរកមួយពោល**សអក្សរ**, សត្វនរកមួយពោល**នអក្សរ**, សត្វនរកមួយពោល**សោអក្សរ** ។ បានឮទៀតថា សត្វនរកទាំងនោះ ក្នុងអតីតភព ជារាជបុត្រ ដែលប្រព្រឹត្ត**បារទារិកកម្ម** (ការប្រព្រឹត្តកន្លងលើប្រពន្ធអ្នកដទៃ) ក្នុងក្រុងសាវត្ថីនេះឯង ។ ពួកគេប្រទូស្តនឹងមាតុគ្រាមដែលមានអ្នកដទៃឃុំគ្រងរក្សា លេងល្បែងកម្សាន្តចិត្ត ធ្វើបាបកម្មយ៉ាងច្រើន កាលត្រូវចក្រគឺមរណៈកាត់ហើយ ក៏បានកើតក្នុង**លោហកុម្ភីនរក** (នរកខ្ទះទង់ដែង) ទាំង ៤ ដែលនៅជិតក្រុងសាវត្ថី ឆេះក្នុងលោហកុម្ភីនរកនោះ អស់ ៦ ម៉ឺនឆ្នាំ កាលផុសឡើងមកលើ ឃើញកណ្ដាប់មាត់លោហកុម្ភីនរក ជនទាំង ៤ នាក់ ក៏ស្រែកយំដោយសំឡេងខ្លាំងៗតាមលំដាប់ថា តើពេលណា ពួកយើងនឹងរួចផុតពីសេចក្ដីទុក្ខនេះ ។ ព្រះបាទ*

កោសលស្តាប់ឮសំឡេងរបស់សត្វនរកនោះហើយ ទ្រង់ត្រូវមរណភ័យគំរាម (ផ្ទំលែងលក់) ស្តេចប្រថាប់គង់ រហូតទាល់អរុណរះឡើង ។ វេលាអរុណរះឡើង ពួកព្រាហ្មណ៍មកសួរការផ្ទំជាសុខរបស់ព្រះរាជា ។

**ព្រះរាជាត្រាស់ថា** លោកអាចារ្យ តើឲ្យយើងផ្ទំជាសុខអំពីណា ថ្ងៃនេះ យើងស្តាប់ឮសំឡេងដែលគួរឲ្យភ័យខ្លាច ៤ មានសភាពបែបនេះ ។

ពួកព្រាហ្មណ៍ក៏នាំគ្នារលាស់ដៃ ។

**ព្រះរាជាសួរថា** មានរឿងអ្វី លោកអាចារ្យ ?

**ពួកព្រាហ្មណ៍ទូលថា** បពិត្រមហារាជ នេះជាសំឡេងអាក្រក់មកគំរាមកំហែង ។

**ព្រះរាជាត្រាស់ថា** ជាកម្មដែលកែប្រែបាន ឬមិនបាន ?

**ពួកព្រាហ្មណ៍ទូលថា** បពិត្រមហារាជ កម្មដែលកែប្រែមិនបាននេះ ទូលព្រះបង្គំបានសិក្សាមកល្អហើយ ។

**ព្រះរាជាត្រាស់ថា** ពួកលោកនឹងធ្វើអ្វី ទើបកែប្រែបាន ?

**ព្រាហ្មណ៍ពោលថា** បពិត្រមហារាជ ពួកទូលព្រះបង្គំមិនអាចធ្វើពិធីកម្មកែប្រែឲ្យធំបានទេ តែទូលព្រះបង្គំនឹងបូជាយញ្ញដោយវត្ថុ ៤ គ្រប់មុខ ហើយកាត់បន្ថយអន្តរាយបាន ។

**ព្រះរាជាត្រាស់ថា** បើយ៉ាងនោះ ពួកលោកចូរប្រញាប់ឲ្យគេចាប់សត្វមួយមុខៗ ៤ ធ្វើចាប់តាំងពីចាបចៀបកប្បាសជាដើម គឺដំរី ៤ សេះ ៤ គោ ៤ មនុស្ស ៤ ហើយបូជាយញ្ញដោយវត្ថុ ៤ គ្រប់មុខ ចូរធ្វើសុវត្ថិភាពដល់យើង ។

**ពួកព្រាហ្មណ៍ទទួលថា** ល្អហើយមហារាជ ។

រួចក៏ឲ្យគេចាប់សត្វតាមសេចក្ដីត្រូវការ យកទៅកាន់រណ្ដៅសម្រាប់បូជាយញ្ញ និងឲ្យគេនាំសសរមកតម្កល់ទុកក្នុងទីនោះ ។ ពួកព្រាហ្មណ៍ជាអ្នកដល់សេចក្ដីឧស្សាហៈថា ពួកយើងនឹងបានស៊ីសាច់និងត្រីច្រើន នឹងបានទ្រព្យច្រើន ដូច្នេះហើយទូលព្រះរាជាថា បពិត្រព្រះសម្មតិទេព គួរនឹងបានវត្ថុនេះ គួរនឹងបានវត្ថុនេះ ដូច្នេះទើបត្រាច់ទៅត្រាច់មក ។

***ព្រះនាងមល្លិកាទេវីចូលគាល់ព្រះរាជាសួរថា*** បពិត្រមហារាជ ហេតុអ្វីបានជាពួកព្រាហ្មណ៍ឧស្សាហ៍ត្រាច់ទៅមកខ្លាំងម្ល៉េះ ?

***ព្រះរាជាត្រាស់ថា*** នែទេវី ប្រយោជន៍អ្វីដោយរឿង (នេះ) ដល់នាង នាងរវល់តែស្រវឹង និងប្រមាទដោយយសរបស់ខ្លួនប៉ុណ្ណោះ នាងមិនដឹងសេចក្ដីទុក្ខរបស់យើងទេ ។

***ព្រះនាងទូលថា*** មានរឿងអ្វី មហារាជ ?

***ព្រះរាជាត្រាស់ថា*** នែទេវី យើងស្ដាប់ឮសំឡេង ដែលមិនធ្លាប់ឮមានសភាពបែបនេះ បន្ទាប់ពីស្ដាប់សំឡេងទាំងនោះមក យើងក៏សួរពួកព្រាហ្មណ៍ថា មានរឿងអ្វីកើតឡើង ពួកព្រាហ្មណ៍ពោលថា នឹងមានអន្តរាយដល់រាជសម្បត្តិ ឬ ភោគសម្បត្តិ ឬ ជីវិតដល់ព្រះអង្គជាប្រាកដ ពួកទូលព្រះបង្គំបូជាយញ្ញដោយសត្វមួយមុខ ៤ ៗ ហើយនឹងធ្វើសុវត្ថិភាព ពួកព្រាហ្មណ៍នោះធ្វើតាមពាក្យយើង នាំគ្នាធ្វើរណ្ដៅ ត្រូវការដោយវត្ថុណាៗ ក៏មកដោយហេតុនោះៗ ។

***ព្រះនាងពោលថា*** បពិត្រព្រះសម្មតិទេព ចុះព្រះអង្គបានសួរព្រាហ្មណ៍ ដែលប្រសើរខ្ពង់ខ្ពស់ លើលោកព្រមទាំងទេវលោក ពីសេចក្ដីសម្រេចនៃសំឡេងទាំងនោះហើយឬ ?

***ព្រះរាជាសួរថា*** នែទេវី ព្រាហ្មណ៍នោះជាអ្នកណា ដែលជាអគ្គព្រាហ្មណ៍ដ៏ប្រសើរខ្ពង់ខ្ពស់លើលោក ព្រមទាំងទេវលោកនោះ ?

***ព្រះនាងទូលថា*** គឺមហាគោតមសម្មាសម្ពុទ្ធ ។

***ព្រះរាជាត្រាស់ថា*** *នៃទេវី យើងមិនបានសួរព្រះសម្មាសម្ពុទ្ធទេ ។*

***ព្រះនាងទូលថា*** *បើយ៉ាងនោះ សូមព្រះអង្គយាងទៅទូលសួរព្រះពុទ្ធចុះ ។*

*ព្រះរាជាកាន់យកពាក្យរបស់ព្រះនាង កាលសោយក្រយាពេលព្រឹករួច ស្ដេចឡើងរថដ៏ប្រសើរ យាងទៅកាន់វត្តជេតពន ថ្វាយបង្គំព្រះសាស្ដា រួចទូលសួរថា*

*បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គស្ដាប់ឮសំឡេង ៤ ក្នុងពេលរាត្រី ហើយបានសួរពួកព្រាហ្មណ៍ ព្រាហ្មណ៍ទាំងនោះពោលថា ទូលព្រះបង្គំបូជាយញ្ញដោយវត្ថុ ៤ ៗ គ្រប់មុខ នឹងធ្វើសិរីសួស្ដី ពួកគេធ្វើកម្មក្នុងរណ្ដៅយញ្ញ ព្រោះការឮសំឡេងទាំងនោះ តើនឹងមានរឿងអ្វីកើតដល់ខ្ញុំព្រះអង្គទេ ?*

***ព្រះសាស្ដាត្រាស់ថា*** *បពិត្រមហារាជ មិនមានរឿងអ្វីទេ សត្វនរកទាំងឡាយដែលកំពុងសោយសេចក្ដីទុក្ខ បានស្រែកយំយ៉ាងនេះ ហើយមិនមែនតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ ដែលមហាបពិត្រឮសំឡេងបែបនេះ សូម្បីព្រះរាជាទាំងឡាយក្នុងកាលមុន ក៏ធ្លាប់ឮសំឡេងនេះដែរ កាលសួរពួកព្រាហ្មណ៍ហើយ (ព្រះរាជានោះ) ក៏ជាអ្នកប្រាថ្នាធ្វើ* ***បសុឃាតយញ្ញ*** *(ការសម្លាប់សត្វបូជាយញ្ញ) តែកាលបានស្ដាប់ពាក្យរបស់បណ្ឌិត ទើបទ្រង់មិនធ្វើ បណ្ឌិតទាំងឡាយពោលចន្លោះ នៃសំឡេង របស់សត្វនរកទាំងនោះ ហើយឲ្យដោះលែងមហាជន ធ្វើឲ្យមានសិរីសួស្ដី ដូច្នេះហើយ កាលព្រះរាជាទូលអង្វរសូមអារាធនា ព្រះសាស្ដាបាននាំអតីតនិទានមកថា ៖*

*ក្នុងអតីតកាល កាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិ ក្នុងនគរពារាណសី ព្រះពោធិសត្វកើតក្នុងត្រកូលព្រាហ្មណ៍ ក្នុងកាសិគ្រាមមួយ កាលចម្រើនវ័យធំហើយ ឃើញទោសក្នុងកាមទាំងឡាយ លះបង់កាម បួសជាឥសី និងបានធ្វើអភិញ្ញានិងសមាបត្តិឲ្យកើតឡើង លេងឈានកីឡា រស់នៅក្នុងព្រៃដែលគួររីករាយ ក្នុងហិមវន្តប្រទេស ។*

*គ្រានោះ ព្រះបាទពារាណសីស្តាប់ឮសំឡេងទាំង ៤ (ទុ-ស-ន-សោ) នេះឯង របស់សត្វនរកទាំង ៤ ហើយទ្រង់ភ័យខ្លាច កាលពួកព្រាហ្មណ៍ក្រាបទូលតាមនិយាមនេះថា បណ្តាអន្តរាយ ៣ យ៉ាង អន្តរាយណាមួយនឹងកើតមានឡើង ទូលព្រះបង្គំនឹងរម្ងាប់អន្តរាយនោះដោយយញ្ញដែលត្រូវធ្វើដោយវត្ថុ ៤ ៗ គ្រប់មុខ ព្រះរាជាក៏យល់ព្រម ។ បុរោហិតរៀបចំធ្វើរណ្តៅយញ្ញមួយអន្ទើដោយពួកព្រាហ្មណ៍ ។ មហាជនត្រូវនាំចូលទៅកាន់សសរយញ្ញ ។*

*ពេលនោះ ព្រះពោធិសត្វធ្វើ**មេត្តាភាវនា**ឲ្យជា**បុរេចារិក** (ធ្វើចិត្តឲ្យប្រកបដោយមេត្តាត្រាច់ទៅខាងមុខ) ប្រមើលមើលសត្វលោកដោយទិព្វចក្ខុ ឃើញហេតុការណ៍នោះ ហើយគិតថា ថ្ងៃនេះ យើងគួរទៅ សិរីសួស្តីនឹងមានដល់មហាជន ដូច្នេះ ទើបហោះឡើងកាន់អាកាសដោយកម្លាំងឫទ្ធិ ទៅចុះក្នុងឧទ្យានរបស់ព្រះបាទពារាណសី អង្គុយលើផែនថ្មមង្គលហាក់ដូចជារូបបដិមាមាស ។*

***គ្រានោះ អន្តេវាសិកជាប្រធានរបស់បុរោហិត ចូលទៅរកអាចារ្យពោលថា** បពិត្រអាចារ្យ ក្នុងវេទទាំងឡាយរបស់ពួកយើង ឈ្មោះថា ការធ្វើសិរីសួស្តី ដោយការសម្លាប់សត្វដទៃ រមែងមិនមាន មិនមែនឬ ?*

***បុរោហិតហាមឃាត់សិស្សនោះថា** អ្នកចូរពេញចិត្តនឹងរាជទ្រព្យ ពួកយើងនឹងបានស៊ីត្រី និងសាច់យ៉ាងច្រើន នឹងបានទ្រព្យច្រើន អ្នកចូរនៅស្ងៀមចុះ ។*

*សិស្សជាប្រធាននោះគិតថា យើងនឹងមិនជាមិត្រ (មិនជាប់ពាក់ព័ន្ធ) ក្នុងរឿងនេះ ដូច្នេះទើបចេញទៅកាន់រាជឧទ្យាន ឃើញព្រះពោធិសត្វ ហើយមកថ្វាយបង្គំ ធ្វើបដិសណ្ឋារៈរួចអង្គុយក្នុងទីដ៏សមគួរមួយ ។*

***ព្រះពោធិសត្វសួរថា** នៃមាណព ព្រះរាជាសោយរាជ្យដោយធម៌ទេឬ ?*

***បុរសនោះពោលថា*** *បពិត្រលោកម្ចាស់ ព្រះរាជាសោយរាជ្យប្រកបដោយធម៌ទេ តែក្នុងពេលរាត្រី (យប់មួយ) ទ្រង់ស្តាប់ឮសំឡេង ៤ ហើយសួរពួកព្រាហ្មណ៍ ពួកព្រាហ្មណ៍ពោលថា នឹងបូជាយញ្ញដោយវត្ថុ ៤ ៗ គ្រប់មុខ ដើម្បីធ្វើសិរីសួស្តី ។ ព្រះរាជាធ្វើបសុឃាតកម្ម ប្រាថ្នាធ្វើសិរីសួស្តីដល់ខ្លួន មហាជនត្រូវនាំចូលទៅ (ចង) នឹងសសរយញ្ញ បពិត្រលោកម្ចាស់អ្នកមានសីលដែលប្រាកដដូចលោក គួរពោលសេចក្តីសម្រេច នៃសំឡេងទាំងនោះ សូមរំដោះមហាជនឲ្យរួចពីមាត់នៃមច្ចុរាជ មិនមែនឬ ?*

***ព្រះពោធិសត្វពោលថា*** *នែមាណព ព្រះរាជាមិនស្គាល់យើងទេ សូម្បីយើងក៏មិនស្គាល់ព្រះរាជានោះ តែយើងដឹងសេចក្តីសម្រេចនៃសំឡេងទាំងនោះ បើព្រះរាជាចូលមកសួរយើង យើងនឹងធ្វើព្រះរាជាឲ្យអស់សេចក្តីសង្ស័យ ហើយសម្តែងប្រាប់ ។*

***អន្តេវាសិកនោះពោលថា*** *បពិត្រលោកម្ចាស់ បើយ៉ាងនោះ លោកចូរនៅក្នុងទីនេះមួយភ្លែត ខ្ញុំនឹងនាំព្រះរាជាមក ។*

***ព្រះមហាសត្វពោលថា*** *ល្អហើយមាណព ។*

*មាណពនោះទៅហើយ ទូលសេចក្តីនោះដល់ព្រះរាជា ហើយនាំព្រះរាជាទៅ ។ លំដាប់នោះ ព្រះរាជាថ្វាយបង្គំព្រះពោធិសត្វ ទ្រង់ប្រថាប់ក្នុងទីដ៏សមគួរមួយ ហើយត្រាស់សួរថា បានឮថា លោកម្ចាស់ដឹងសេចក្តីសម្រេចនៃសំឡេងដែលយើងបានឮ ពិតមែនឬ ?*

***ព្រះមហាសត្វទូលថា*** *ពិតមែនហើយមហារាជ ។*

***ព្រះរាជាត្រាស់ថា*** *ចឹងសូមលោកម្ចាស់ប្រាប់ (យើង) ផង ។*

***ព្រះពោធិសត្វទូលថា*** *បពិត្រមហារាជ ក្នុងភពមុន សត្វនរកទាំងនេះប្រព្រឹត្តខុសក្នុងប្រពន្ធដែលអ្នកដទៃឃុំគ្រងរក្សា ទើបកើតក្នុងលោហកុម្ភីនរកទាំង ៤ ដែលនៅជិតនគរពារាណសី កាលឆេះរាងកាយ (មានអាការ) ដូចជាពពុះទឹក ក្នុងទឹកលោហៈប្រៃ លិចចុះ*

ក្រោមអស់ ៣ ម៉ឺនឆ្នាំ ទើបទៅដល់បាទខ្ទះ កាលផុសឡើងមកលើ ឃើញមាត់ខ្ទះ ក៏ដោយកាល ៣ ម៉ឺនឆ្នាំដែរ សម្ទឹងមើលចេញមកក្រៅ ជនទាំង ៤ (ម្នាក់ៗ) ប្រាថ្នាធ្វើគាថាឲ្យពេញបរិបូណ៌ទាំង ៤ គាថា តែកាលមិនអាចនឹងធ្វើបានយ៉ាងនោះ ពួកគេម្នាក់ៗ ធ្វើបានតែអក្សរ ១ ប៉ុណ្ណោះ ហើយក៏ត្រូវមុជចុះក្នុងលោហកុម្ភីនរកម្ដងទៀត ។

បណ្ដាសត្វនរកទាំងនោះ សត្វដែលពោលទុអក្សរ ហើយមុជចុះនោះ ជាអ្នកប្រាថ្នានឹងពោលយ៉ាងនេះថា

**ទុជ្ជីវិតមជីវិម្ហ, យេ សន្តេ ន ទទម្ហសេ;**
**វិជ្ជមានេសុ ភោគេសុ, ទីបំ ជាកម្ហ អត្តនោ។**

***ពួកយើងដែលមិនបានឲ្យទាន បានជាពួកយើងរស់នៅដោយត្រដាបត្រដួស កាលភោគៈទាំងឡាយមាន ពួកយើងមិនបានធ្វើនូវទីពឹងបម្រុងខ្លួនសោះ ។***

ព្រះពោធិសត្វពោលថា សត្វនរកមិនអាចនឹងធ្វើគាថានោះឲ្យពេញបរិបូណ៌ ដូច្នេះហើយ លោកទើបពោលគាថានោះឲ្យពេញបរិបូណ៌ដោយញាណរបស់ខ្លួន ។ សូម្បីក្នុងគាថាដ៏សេសក៏មានន័យនេះដូចគ្នា ។

បណ្ដាសត្វនរកទាំងនោះ គាថានេះរបស់សត្វដែលពោលសអក្សរ ដោយប្រាថ្នាពោលថា

**សដ្ឋិ វស្សសហស្សានិ, បរិបុណ្ណានិ សព្ពសោ;**
**និរយេ បច្ចមានានំ, កទា អន្តោ ភវិស្សតិ។**

***ពួកយើងឆេះ ក្នុងនរកគ្រប់ជា ៦០០០០ឆ្នាំ ដោយអការៈទាំងពួងហើយ កាលណានឹងមានទីបំផុត ( នៃទុក្ខ) ។***

*គាថានេះរបស់សត្វ ដែលពោលនអក្សរ ដោយប្រាថ្នាពោលថា*

**នត្ថិ អន្តោ កុតោ អន្តោ, ន អន្តោ បដិទិស្សតិ;**
**តទា ហិ បកតំ បាបំ, មម តុយ្ហញ្ច មារិសា។**

*ម្នាលអ្នកស្មើនឹងខ្ញុំ ទីបំផុត (នៃទុក្ខយើង) មិនមានទេ ទីបំផុតនឹងមានមកពីណា ទីបំផុតនឹងមិនប្រាកដទេ ព្រោះថា ខ្ញុំនិងអ្នកបានធ្វើបាប ក្នុងកាលនោះ ។*

*គាថានេះរបស់សត្វ ដែលពោលសោអក្សរ ដោយប្រាថ្នាពោលថា*

**សោហំ នូន ឥតោ គន្ត្វា, យោនឹ លទ្ធាន មានុសឹ;**
**វទញ្ញូ សីលសម្បន្នោ, កាហាមិ កុសលំ ពហុំ។**

*ខ្ញុំនោះ លុះទៅអំពីទីនេះ បានកំណើតជាមនុស្ស ចាប់អំពីដឹងក្តីទៅ សូមជាអ្នកបរិបូណ៌ដោយសីល ធ្វើកុសលឲ្យច្រើន ។*

*ពាក្យថា* **ទុជ្ជីវិតមជីវិម្ហ** *បានដល់ ការប្រព្រឹត្តទុច្ចរិត ៣ ឈ្មោះថា ជីវិតអាក្រក់លាមក*

*។*

*ព្រះពោធិសត្វពោលគាថានីមួយៗ ដូច្នេះហើយ ឲ្យព្រះរាជាដឹងថា បពិត្រមហារាជ សត្វនរកចង់ពោលគាថានេះឲ្យពេញបរិបូណ៌ តែមិនអាចនឹងពោលយ៉ាងនោះ ព្រោះភាពជាអ្នកមានបាបច្រើនរបស់ខ្លួន គេកាលសោយវិបាកកម្មរបស់ខ្លួន ទើបស្រែកយំយ៉ាងនេះ ។ ឈ្មោះថា អន្តរាយពីការស្តាប់សំឡេងនោះជាបច្ច័យ រមែងមិនមានដល់ព្រះអង្គទេ សូមព្រះអង្គកុំភ័យឡើយ ។ ព្រះរាជាបញ្ជាឲ្យដោះលែងមហាជន ឲ្យរាជបុរសត្រាច់វាយសុវណ្ណភេរីប្រកាស និងឲ្យទម្លាយរណ្តៅយញ្ញ ។ ព្រះពោធិសត្វបានធ្វើសិរីសួស្តីដល់មហាជនហើយ*

*ស្នាក់នៅទីនោះ អស់ពីរបីថ្ងៃ រួចក៏ទៅកាន់ព្រៃហិមពាន្តវិញ ជាអ្នកមិនមានឈានសាបសូន្យ បានកើតក្នុងព្រហ្មលោក ។*

*ព្រះសាស្តានាំព្រះធម្មទេសនានេះមកហើយ ទ្រង់ប្រកាសសច្ចធម៌ និងប្រជុំជាតកថា*

**តទា បុរោហិតស្ស ជេដ្ឋន្តេវាសិកមាណវោ សារិបុត្តោ អហោសិ** *មាណពជាប្រធានអន្តេវាសិករបស់បុរោហិត ក្នុងកាលនោះ បានមកជាសារីបុត្រ*

**តាបសោ បន អហមេវ អហោសឹ** *ចំណែកតាបស គឺ តថាគត នេះឯង ។*

*លោហកុម្ភិជាតក ចប់ ៕*

(*ជាតកដ្ឋកថា សុត្តន្តបិដក ខុទ្ទកនិកាយ ជាតក ចតុក្កនិបាត បុចិមន្ទវគ្គ លោហកុម្ភិជាតក បិដកលេខ ៥៨ ទំព័រ ២០០*)

*ថ្ងៃ សុក្រ ៥ រោច ខែស្រាពណ៍ ឆ្នាំច សំរិទ្ធិស័ក ច.ស. ១៣៨០ ម.ស. ១៩៤០*

*ថ្ងៃទី ៣១ ខែ សីហា ព.ស. ២៥៦២ គ.ស.២០១៨*

*ដោយស.ជ.វ.ថ.*